Ontario
Ministry of
Culture and
Recreation

# ច្រកផ្លូវទៅរក ការងារ និងមុខរបរ

## ការបង្កើនលទ្ធផល ពីការរកការងារ និងការប្រកបរបររកស៊ី ដោយមានប្រសិទ្ធិភាព



# មាតិការរឿង

ទំព័រ


- សេចក្ដីផ្ដើម 2
- ការរកការងារ 5
- ការសំរេចចិត្ត 5
- ការរៀបចំខ្លួន 8
- ការរើសរកការងារ 12
- ជោគជ័យនៅពេលសម្ភាសន៍ 16
- គិតពីកិច្ចការដែលត្រូវធ្វើ 18
- ការត្រូវបំពេញ 19
- ការរកទទួលទាន 23
- ការធ្វើម្ចាស់ខ្លួនឯង 23
- ការផ្សាយពីខ្លួនអ្នក 27
- ការការពារច្បាប់ 28
- ការទុកឯកសារ 30
- ការធ្វើនិយោជនជោគជ័យ 30
- ការពង្រីក 31



សេចក្តីផ្តើម:

បើអ្នកជាមនុស្សពេញវ័យដែលរកការធ្វើ ស្ទើរតែទាំងអស់គ្នានិងបានការធ្វើៗ ដោយហេតុនេះហើយបានជាលេខាធិការដ្ឋានយុវជនខេត្រញូវយ៉ក បានរៀបចំសៀវភៅមគ្គុទ្ទេសក៍នេះ ។ គោលបំណងសៀវភៅនេះគឺបង្រៀនអ្នកឲ្យចេះការប្រជួញ ដែលរកការងារធ្វើនៅសម័យនេះ ។

ចូរអានសៀវភៅនេះដោយយកចិត្តទុកដាក់ ហើយរៀនពី របៀបដែលបង្កើតឈ្នះអ្នកក្នុងការរកការងារធ្វើ ។ ចូរគិតនូវគន្លឹះដែលបានត្រឹមត្រូវ និងរករបៀបធ្វើឲ្យបានជាប្រយោជន៍ដល់អ្នក ។ ចូរអានត្រង់ផ្នែក ការបង្កើតការដោយខ្លួនអ្នក ព្រោះអ្នកមិនត្រូវបោះបង់គំនិតបញ្ចេញគោលបំណងអ្នកក្នុងការបង្កើតហាងតូចនិងមានកំរៃមួយ ។

ពេលអ្នកធ្វើជីវប្រវត្តិនិងធ្វើលិខិតសុំការធ្វើ ចូរធ្វើតាមគំរូៗ ចូរចាំការផ្តល់គំនិតរបស់យើង ពេលអ្នកទៅដល់ពេលសំភាសន៍ ហើយចូរគិតនូវគន្លឹះបញ្ជាក់ពីការដែលអ្នកបានធ្វើ ដើម្បីឲ្យបានបង្ហាញថាអ្នកបានធ្វើល្អគ្រប់ហើយអ្នកអាចបានការងារល្អធ្វើ ។

ការសំខាន់បំផុតត្រូវរកការងារតាមបុគ្គលិកវិជ្ជា ហើយព្យាយាម ទោះបីអ្នកជួបប្រទះជាច្រើនដងក៏ដោយនូវពាក្យ "យើងស្ដាយណាស់ដោយមិនបានជ្រើសរើសអ្នក" ។ ទោះបីអ្នកខ្វះការពិសោធ និងការប៉ិនប្រសប់ស៊ើបរកការងារក៏ដោយ ក៏អ្នកនឹងបានប្រយោជន៍ខ្លះពុំខានអ្នកដែរ ។

ចូរចាំជានិច្ចថា អ្នកនៅក្មេង មានកំឡាំងហើយមានចិត្តចង់ធ្វើការ ។ ល្មមធ្វើឲ្យនាយកទាំងឡាយជួលអ្នកនឹងរៀន នេះ នោះអ្នកនឹងមានបទពិសោធ និងផ្លូវប្រកបវិស័យ ។

នៅពេលមានការចាំបាច់ផង ខេត្តអុនតារីយោ យើងធ្វើយ៉ាងប្រឹងប្រែងដើម្បីជួយអង្គការទាំងអស់ ដែលរដ្ឋាភិបាលរៀបធ្វើតំរោងការងារឲ្យយុវជនសំរាប់យុវជន ។ តំរោងការងារខ្លះ ដែលយើងទទួលខុសត្រូវគឺ : បង្កើតការងាររដូវក្ដៅចំនួនជិត ១០ ០០០ នៅក្រសួងរដ្ឋការ និងទីភ្នាក់ងារផ្សេងៗ ។

STUDENT VENTURE CAPITAL:

ន័យថាឲ្យខ្ចីប្រាក់រហូតដល់ ១ ០០០ ដុល្លារ ដល់និស្សិតដែលមានអាយុពី១៦ ឆ្នាំឡើងទៅ ដើម្បីជួយការពង្រីកលក្ខណៈព្រាណ នៅរដូវក្ដៅ ។

ONTARIO SECONDARY SCHOOL/COOPERATIVE EDUCATION PROGRAM:

ផ្ដល់ការងារបណ្ដោះអាសន្នក្នុងរដ្ឋាភិបាលឲ្យនិស្សិតដែលរៀនយកវិជ្ជាជីវៈឲ្យមានការពិសោធន៍ក្នុងការធ្វើការងារ ។

ONTARIO CAREER WEEK:

រៀងរាល់ឆ្នាំ និស្សិតអាចចូលរួមក្នុងសកម្មភាពផ្សេងៗ ដែលធ្វើឲ្យមានការចេះដឹង និងមានពត៌មានក្នុងមុខរបរខ្លួនទៅថ្ងៃក្រោយ ។

ONTARIO YOUTH EMPLOYMENT PROGRAM:

ពេលរដូវក្ដៅ មានបង្កើតការងារថ្មីចំនួនប្រហែល ៥០ ០០០ នៅក្រុមការ និងក្នុងសាលាផ្សេងៗ ដោយរដ្ឋាភិបាលផ្ដល់ប្រាក់ឧបត្ថម្ភមួយចំណែក ។

ONTARIO CAREER ACTION:

ជួយយុវជនដែលរសាត់ចោលសាលារៀន មានតំរេះអ៊ីយូយ ហើយមិន
មានការពិសោធ ។

លេខាធិការដ្ឋានយុវជនដែលត្រូវគុណនារីយោបន្ទុកការយកចិត្ត
ទុកដាក់ក្នុងលក្ខណបុគ្គលិកដែលប៉ះទង្គិចដល់យុវជនទៅតែត្រូវហើយ ។
ការរកការធ្វើ ការខ្វះការប៉ិនប្រសប់ ការសិក្សា ជា
កត្តាខ្លះដែលយើងមានដឹង ហើយយើងកំពុងសាកល្បងដោះស្រាយៗ
យើងចង់ដឹងពីចំណោទរបស់អ្នក និងយោបល់អ្នកស្តីពីកម្មវិធីរបស់
រដ្ឋាភិបាលចំពោះយុវជន ។ ពិតមែនតែយើងមានទីប្រឹក្សា
ប៉ុន្តែយើងត្រូវការបញ្ញាពេលបច្ចុប្បន្នរបស់អ្នក និងយោបល់អ្នកទៅ
អ្នកទទួលខុសត្រូវ ។

អ្នកសាចសរសេរទៅយើងតាមអាស័យដ្ឋាននេះ :

ONTARIO YOUTH SECRETARIAT
QUEEN PARK, TORONTO, ONTARIO
M7A 1Z1



ការរកការងារ:

-ការសំរេចចិត្ត:

ការចង់ធ្វើការមានមូលហេតុច្រើនណាស់ ។ ការចង់បានប្រាក់ ចង់បានការពិសោធ និងចង់ចូលសេចក្តីសោភ័ណក្នុងសាកជីវិត ជាមូលហេតុខ្លះធ្វើឲ្យដឹងថា ហេតុអ្វីបានជាមនុស្សរកការងារ ហើយធ្វើការងារ ។

អ្នកមិនត្រូវខ្វល់ពីហេតុដែលបណ្តាលឲ្យអ្នកចង់ធ្វើការទេ ចូរក្រឡេកមើលខ្លួនអ្នក និងការងារដែលមាន ។ រួចពិនិត្យសំនួរខាងក្រោមនេះឲ្យបានម៉ត់ចត់ :

-ហេតុអ្វីបានជាខ្ញុំចង់ធ្វើការ ?

-តើគោលដៅបន្ទាន់ និងអនាគតរបស់ខ្ញុំអ្វី ?

-តើខ្ញុំមានកោសល្យ និងការប៉ិនប្រសប់អ្វីខ្លះ ?

-តើការងារអ្វី ប្រាក់ខែប៉ុន្មាន ដែលខ្ញុំសង្ឃឹមថានឹងបាននៅក្នុងតំបន់ខ្ញុំ

-តើខ្ញុំត្រូវផ្លាស់ទីលំនៅឬទេ ដើម្បីធ្វើអនាគតខ្ញុំឲ្យបានចំរើន

-តើខ្ញុំអាចធ្វើការអ្វីខ្លះឲ្យបានប្រាក់ ?

បន្ទាប់ពីអ្នកសួរខ្លួនអ្នកនូវសំនួរនេះ ចូរអ្នកសួរម្តងទៀត ។ ចូរអ្នកសួរចំពោះអ្នក ដែលជាមនោសញ្ចេតនារបស់អ្នក និងធ្វើឲ្យអ្នកមានទំលាប់នេះ និងទីដៅបញ្ជាក់អំពីចំពោះខ្លួនអ្នក ។ ចូរអ្នកដឹងឲ្យពិតប្រាកដពីអ្វីដែលអ្នកចង់ និងពីព្រោះអ្វី ។

បើអ្នកឆ្លើយសំនួរនេះដោយត្រង់ និងយកចិត្តទុកដាក់ អ្នកនឹងដឹងថា ការងារអ្វី និងប្រាក់ខែប៉ុន្មាន ដែលអ្នកស្វែងរក ។ ដូច្នេះអ្នកនឹងត្រូវរៀនសំភាសខ្លួនអ្នក ពីព្រោះសំនួរទាំងអស់នេះនឹងត្រូវជួយអ្នកសួរអ្នកជាពុំខាន ។

បន្ទាប់ពីការរៀបចំនេះ ដំណាក់ទីពីរ អ្នកត្រូវប្រុងប្រៀបពីការសំភាសន៍លើរកការងារដែលអ្នកចង់ធ្វើ ។ក្នុងករណីច្រើន ការរកការធ្វើត្រូវសំភាសន៍ច្រើនសារទៀត ជួនកាលរាប់ខែទើបរកការបាន ។

ដូច្នេះ បើអ្នករកការងារត្រង់កន្លែងផ្សាយក្នុងកាសែត ឬ ផ្ញើពាក្យសុំ ឬទៅឲ្យគេសំភាស ចូរគិតថា បើគេមិនឲ្យកិច្ចការអ្នក នោះមិនមែនមានន័យថា ខុសអ្នកទេ ។

ចូរកុំយកចិត្តទុកដាក់ពីការដែលគេមិនយកអ្នក ។ចូរអ្នកជឿខ្លួនអ្នក តាំងចិត្តឲ្យខ្ពស់ ឡើង ។ ចូរសរសេរសំបុត្រសុំឲ្យគេធ្វើសំភាស ព្រោះបើអ្នកឈប់ព្រួយថាអ្នកមិនសូវមានសង្ឃឹមក៏ដោយ ។ ជួនកាលនៅដែលអ្នកដាក់ពាក្យនោះ វាពុំមានកន្លែងទំនេរ តែក្រោយមកបើមានកន្លែងទំនេរគេនឹងទាក់ទងជាមួយអ្នកមិនខាន ។ ទុកជាអ្នកពុំបានទទួលជោគជ័យក៏ដោយ ក៏អ្នកនឹងពេញចិត្តចំពោះខ្លួនអ្នកក្នុងការខំស្វែងរកការងារ។ បើអ្នកនៅតែបន្តទៅការស្វែងនេះ អ្នកនឹងមានឱកាស ប្រហែល ១០០ ដង ក្នុងការរកការធ្វើ ។

ចូរកុំភ្លេចថា មានអ្នកសុំការធ្វើជាច្រើនដែលមានការប្រលង និងមានគុណសម្បត្តិដូចអ្នក តែសាកប្បកិរិយាអ្នកអាចធ្វើឲ្យអ្នកមានផ្លូវច្រើនជាង។

តើអ្នកត្រូវធ្វើដូចម្តេច បើមានការដែលមិនត្រូវគោលដៅអ្នក ? ចូរពិនិត្យមើលការងារនេះឲ្យបានល្អិតល្អន់ ព្រោះប្រហែលជាមានតែការងារមួយនេះទេ ដែលអ្នកនឹងត្រូវទទួល។

ចូរចាំថាការងារនិមួយៗសុទ្ធតែមានប្រយោជន៍ ហើយការងារថ្មីក៏ជាឱកាសធ្វើប្រយោជន៍ឲ្យអ្នក បើអ្នកធ្វើការនោះ ។ ការងារមិនត្រឹមតែធ្វើឲ្យអ្នកបានប្រាក់ទេ វាព្រមទាំងធ្វើឲ្យអ្នកបានការពិសោធមួយដ៏មានប្រយោជន៍ ។ ពេលណាអ្នករកការងារថ្មីទៀត អត្ថប្រយោជន៍អ្នកនៅត្រង់អ្នកអាចបង្ហាញថាអ្នកធ្លាប់កាន់តំណែងទទួលខុសត្រូវមួយពីមុនមកហើយ ។ នេះជាកត្តាលើកឲ្យអ្នកមានភ័ព្វវាសនានឹងទទួលការងារថ្មីថ្មី។

មុននឹងអ្នករកការងារធ្វើ ចូរសំរេចចិត្តជាដំបូងថាអ្នកនឹងបានការងារធ្វើជាពុំខាន ហើយអ្នកត្រូវតែតាំងចិត្តថានឹងទទួលធ្វើការងារអ្វីទាំងឡាយដែលអ្នកអាចរកបាន ។ ចូរតាំងចិត្តឲ្យបានម៉ឺងម៉ាត់ ក្នុងគំនិតធ្វើអ្វីមួយ ឲ្យបានសំរេចដូចចិត្តជាជាងនៅអង្គុយចាំព្រេងវាសនា ។




ការរៀបចំខ្លួន :

ប័ណ្ណការងារ

បើអ្នកមិនទាន់មានប័ណ្ណនេះទេ សូមទៅសុំនៅក្រសួងការងារ នៅសង្កាត់អ្នក ។

ចូរយកទៅជាមួយនូវសំបុត្រកំណើត ។បើអ្នកកើតនៅខែត្រ កេបិច QUEBEC ឬនូវញូវទៀន NEWFOUNDLAND អ្នកអាចយកសំបុត្រដែលវិហារចេញអោយទៅជាមួយ ។ សំបុត្រដែលអ្នកត្រូវយកទៅជាមួយនោះ សំបុត្របើកបរថយន្ត ឬ ប័ណ្ណសាលារៀន ប័ណ្ណបណ្ណាល័យ ប័ណ្ណសមាជិកសង្គម ណាមួយ ឬសំបុត្រស្នាមអ្វីមួយដែលមានឈ្មោះអ្នកគឺប្រើការបានដែរៗ បើអ្នកកើតនៅក្រៅកាណាដា អ្នកត្រូវមានប័ណ្ណសញ្ជាតិ កាណាដា ឬក្រដាសលេខ ១000 IMMIGRATION 1 000 FORM,

ឬសំបុត្រឆ្លងដែនដែលមានបោះត្រាជាអ្នកចំណូលថ្មី PASSPORT WITH YOUR LANDED IMMIGRANT STAMP

បន្ទាប់មកអ្នកត្រូវបំពេញក្រដាសពាក្យ ហើយអ្នកទទួលប័ណ្ណ ការងារនេះក្នុងរយៈពេល 4 អាទិត្យតាមប្រៃសណីយ៍

ទី៧ ។ ចូរសុំប័ណ្ណនេះឲ្យបានដាច់ ព្រោះថាអ្នកត្រូវមានប័ណ្ណ នៅពេលអ្នកត្រូវគេសំភាស ។

បើអ្នកមានសំនួរ ចូរទូរស័ព្ទទៅក្រសួងការងារនៅជិតអ្នក ។ អ្នកអាចចំណេញពេលវេលាបានច្រើនមុនពេលអ្នកទៅក្រសួងនេះ ។

## ជីវប្រវត្តិ

ជីវប្រវត្តិគឺជារឿងខ្លីមួយរៀបរាប់ពីខ្លួនអ្នក ដែលធ្វើឲ្យនាយជាង EMPLOYER ដឹងថាអ្នកអាចធ្វើការបានឬមិនបាននៅក្នុងអង្គការរបស់គេ ។

សូមផ្ញើជីវប្រវត្តិនិងសំបុត្រអ្នកសុំការងារអ្វីមួយទៅជាមួយ ។ ហើយសូមកុំភ្លេចយកលិខិតជីវប្រវត្តិ ១ សន្លឹកទៅជាមួយនៅពេលអ្នកត្រូវគេសំភាស ។

ពេលអ្នកធ្វើជីវប្រវត្តិ ចូរធ្វើឲ្យវាខ្លី រៀបរាប់ការសំខាន់ៗដែលអ្នកបានធ្វើ ។ បំភ្លេចរបាយការណ៍ដែលបានធ្វើមិនល្អ ។ សូមកុំភ្លេចដាក់ជាដាច់ខាតនូវ :

ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត

អាស័យដ្ឋាន ទូរស័ព្ទ នៅក្នុងជីវប្រវត្តិអ្នក ។

### ការអប់រំ :

សូមចុះឈ្មោះសាលាទាំងអស់ដែលអ្នកបានរៀន និងកាលបរិច្ឆេទទទួលសញ្ញាប័ត្រ បញ្ជាក់ត្រង់កន្លែងដែលបានលេខល្អ រាយបញ្ជីដែលបានទទួលរង្វាន់ និងបញ្ជីកិច្ចការ ឬក្រុមដែលអ្នកបានលេងនៅសាលា ។ ជួនកាលការប៉ិនប្រសប់ក្នុងឋានៈជាលេខាធិការក្រុមល្បែងមានតំលៃជាងការប៉ិនប្រសប់នៃការរៀនសូត្របានលេខខ្ពស់ ។

### ការពិសោធន៍ក្នុងការងារ

ចូរធ្វើបញ្ជីការងារដែលអ្នកបានធ្វើ រាប់រៀបពីការងារថ្មី ទៅការងារចាស់ ចុះកាលបរិច្ឆេទ រាប់រៀបពីលក្ខណៈនៃការដែលទទួលខុសត្រូវ និងបញ្ជាក់ពីការឡើង

លុយ ឬបុណ្យស័ក្តិ បើសិនជាមាន ។

បើអ្នកមិនដែលធ្វើការ ចូររាប់រៀបពីការងារដែលអ្នកជួយអ្នកដទៃ ដោយបូកបញ្ចូលនិងការងារស្ម័គ្រចិត្ត ។

ការចូលចិត្ត

ចុះឈ្មោះក្លិប ឬអង្គការដែលអ្នកបានចូលជាសមាជិក ហើយនិងសកម្មភាព និងការដែលអ្នកធ្វើនៅពេលទំនេរ ។

គោលដៅ

អ្នកគួរតែបញ្ជាក់ បើអ្នកមានការងារអ្វី ឬគោលដៅវែងឆ្ងាយ ។ ទោះជាណាក៏ដោយ ក៏អ្នកបានបង្ហាញនយោជកថា អ្នកជាមនុស្សប្រាថ្នាខ្ពង់ និងមានភាពក្លាហាន។

រេហ្វើរិនស៍

អ្នកត្រូវរកឈ្មោះមនុស្សពីរនាក់ដែលអ្នកស្គាល់ច្បាស់ ឧទាហរណ៍ ដូចជា គ្រូចាស់ ឬនយោជកចាស់ជាការល្អ ។ចូរកុំឱ្យឈ្មោះបងប្អូនរួមពោះ ទោះបីអ្នកទាំងនេះជាអ្នកល្អក៏ដោយ ។ អ្នកត្រូវតែសុំអនុញ្ញាតពីគេមុនសិន រួចសុំចុះក្នុងជីវប្រវត្តិអ្នក។

តពីនេះជាគំរូជីវប្រវត្តិ ។ របៀបធ្វើជីវប្រវត្តិមានច្រើនយ៉ាង ហើយអ្នកអាចឃើញគំរូផ្សេងៗនៅបណ្ណាល័យ ។ ពេលអ្នកសរសេរជីវប្រវត្តិអ្នក ចូរអ្នកចាប់ផ្តើមពីការសំខាន់ដែលបានធ្វើ ទោះបីពីការរៀនក្តី ឬពីការងារក្តី ។

## ជីវប្រវត្តិគ្រូ

| | | | |
|---|---|---|---|
| ផ្ទះ ៥ | ថ្ងៃកំណើត | : | ១០ កក្កដា ១៩៥៥ |
| ២៣ វិថីចំការកទាម | សញ្ជាតិ | : | ខេមរៈ |
| តូរ៉ុនតូ អនតារីយ៉ូ | កំពស់ | : | ៥ហ្វីត ៤អ៊ីញ |

### ការសិក្សា

១៩៧៥ បញ្ចប់ថ្នាក់: វិទ្យាល័យពហុបច្ចេកទេសរ៉ីឈូន តូរ៉ុនតូ
ផ្នែកទេសកាលែង វិស្វកម្មសិក : បង្រៀន
គណិត បង្រៀនវិទ្យាសាស្ត្រ ហើយបង្ហាត់
បង្រៀន និងការសិក្សាថ្នាក់ ១២ និង ១៣
Secondary School.

១៩៧៦_៧៤ សាលាវិទ្យាល័យគិតទោល រៀនចប់ឆ្នាំ
រៀនអង់គ្លេស ភាសាង និងប្រវត្តិសាស្ត្រ
ពិន្ទុ:៧២ ភាគរយ ។

### ការពិសោធន៍

| | | |
|---|---|---|
| ឧសភា ៧៧ | ក្រុមហ៊ុន អ៊ិត តុន អ្នកលក់ | |
| កញ្ញា ៧៧ | ការងារនៅផ្ទះទៅ បម្រើភ្ញៀវ | |
| ឧសភា ៧៦ | បង្ហាត់ហ្វឹកហ្វឺនក្មេងប្រកាន់ត្រូវអ្នកទេះ | |
| កញ្ញា ៧៦ | ចំនួន ១០ នាក់ ពីអាយុ ៨ ទៅ ១០ឆ្នាំ | |
| ខួរ ៧៣ | ហាង Zellers ធ្វើការ ១៤ | |
| | ម៉ោង ១អាទិត្យ ពេលរៀន ។ | |
| កញ្ញា ៧៥ | ធ្វើការពេញម៉ោងពេលវិស្សមកាលខែ | |
| | ឧសភា_កញ្ញា បម្រើភ្ញៀវ គិតលុយរាប់ | |
| | ក្នុងឆ្នាំង និងចិញ្ចឹមរាសរឹងមាំដេរ ។ | |

### សកម្មភាពនិងការចូលចិត្ត

លេងកីឡាវាយកូនបាល់ផ្លូវចំការមន និង ហែលទឹក ថតរូប ធ្វើម្ហូបភោជន៍ ដើរ។

### យោង

លោក អ៊ិន ហួ ម៉ាយ អ្នកស្រី រ៉ូប៊ើតា ប្រែយ
គ្រូបង្ហាត់ផ្នែកវិទ្យាសាស្ត្រ អ្នកប្រព្រឹត្តកិច្ច
វិទ្យាល័យពហុបច្ចេកទេសរ៉ីឈូន ផ្លូវចំការមន ហ្សាណលហមនី
តូរ៉ុនតូ អនតារីយ៉ូ ៣៧ ផ្លូវចំការមន តូរ៉ុនតូ



## ការសំរៀងនានាយ៉ាងល្អការរកការងារ

ត្រូវចាំថាពេលរកការងារណាដែលគេត្រូវការធ្វើការ និង ត្រូវតែឲ្យគេដឹងថាអ្នកជាបុគ្គលម្នាក់កំពុងរកការងារធ្វើ ។

ចូរអនុវត្តការទាក់ទងរបស់អ្នក :

ចូរកុំអៀនខ្មាសនឹងការសួរមិត្តភ័ក្ដ្រ ឬបងប្អូន ដែលគេមានការធ្វើ ។ចូរប្រាប់គេពីការងារអ្វីដែលអ្នករក និងសុំគេឲ្យប្រាប់អ្នក បើសិនជាមានការងារនោះ ។ ចូរសុំឲ្យគេសួរមិត្តភ័ក្ដ្រគេ ឬអ្នកធ្វើការជាមួយគេ ។ គេអាចដឹងថាមានការទំនេរ ដែលគេមិនទាន់ផ្សាយ ។ សុំអនុញ្ញាតិយកឈ្មោះគេប្រើបើគេប្រាប់ការងារទំនេរដល់អ្នក ។

ចូរទៅរកការងារនៅមន្ទីការងារ :

អ្នកអាចទៅក្រសួងការងារការណ៍ថា ការិយាល័យរកការងារតាមសាលាជាន់ខ្ពស់ និងការិយាការងារឯកជនដែលមានជំនាញការខាងការរកការងារ ។ សូមមើលអត្ថបទ "ទៅជាមួយនៅពេលសំភាស" ។

ចូរឆ្លើយទៅនឹងយោធកម្ម :

ចូរអ្នកប្រាប់គេថាអ្នកជាអ្នកណា និងប្រាប់ពេលដែលអ្នកធ្លាប់ធ្វើការពីមុនមកជាមួយគេ ។ ចូរសួរគេថា តើមានការងារទំនេរទេ ។ បើគ្មានទេ អ្នកគួរសួរគេថា តើមានអ្នកណាងទៀតទេដែលអ្នកអាចសុំគេធ្វើសំភាស ។អ្នកអាចសុំឈ្មោះអតិតៈនយោជកអ្នកដាក់ក្នុងយោងរបស់អ្នក ។

ការសន្ទនាជាមួយមន្ត្រីទេស ឬទីប្រឹក្សាអ្នក ៖

អ្នកទាំងនេះជួយប្រាប់អ្នកអំពីការងារដែលនៅទំនេរ ។ អ្នកត្រូវសុំអ្នកទាំងនេះឲ្យប្រាប់នៅពេលមានការទំនេរ ។

ចូរអានការផ្សាយ ៖

សូមអានរាល់ថ្ងៃត្រង់ផ្នែកផ្សព្វផ្សាយពីការងារ និងអានត្រង់ផ្នែក "ត្រូវការជំនួយតាមរដូវ" ។ ចូរកុំភ្លេចអានការផ្សាយប្រចាំអាទិត្យ ។ កុំតូចចិត្តឲ្យសោះ នៅពេលអ្នកឃើញក្នុងការផ្សាយថា "ត្រូវមានការពិសោធ" ។ បើអ្នកយល់ឃើញថាអ្នកអាចធ្វើការនោះបាន អ្នកត្រូវតែទៅសុំការនោះ ព្រមទាំងបង្ហាញនូវសេចក្តីអង់អាច និងរីករាយរបស់អ្នកសំខាន់ជាងការខ្វះការពិសោធ ។

ការចេញដើររកការងារ ៖

ការទៅជួបនយោជកផ្ទាល់ខ្លួនជាការមួយល្អណាស់នៃការរកការងារ ។ ម្យ៉ាងទៀត វាជាការមួយសំខាន់ និងមានប្រសិទ្ធភាពជាងការផ្ញើសំបុត្រ ។ ការទៅផ្ទាល់ ជាការសំដែងនៃការចាប់ផ្តើមគំនិតរបស់អ្នក និងការចង់ធ្វើការពិតៗរបស់អ្នក ។ របៀបនេះធ្វើឲ្យអ្នកមានឱកាសសួររកការងារផ្សេងៗទៀត ។ សូមបញ្ជាក់ថា របៀបរកការធ្វើនេះ អាចផ្តល់ផលច្រើនជាង ។

ពាក្យសុំការងារធ្វើ ៖

បើអ្នកដឹងថាមានការងារ ឬអ្នកឃើញការចុះផ្សាយក្នុងការផ្សាយ អ្នកត្រូវតែទូរស័ព្ទមកដើម្បីសុំគេធ្វើសំភាស ។ ប៉ុន្តែបើអ្នកត្រូវសរសេរពាក្យផ្ញើតបនិងការផ្សាយ ចូរអ្នកផ្ញើជីវប្រវត្តិទៅជាមួយនិងសំបុត្រអ្នកជាកុំខាន ។

សំបុត្រសុំធ្វើការជាសំបុត្រសុំបង្ហាញខ្លួនអ្នកទៅនយោជក ។ ការចាប់អារម្មណ៍ដំបូងជាការសំខាន់ណាស់ ។ អ្នកមិនត្រូវស្លៀកពាក់ខោអាវក្រខ្វក់ និងទុកសក់កន្ទ្រើង ហើយនិង

មិនត្រូវធ្វើសំបុត្រកខ្វក់សរសេរនិងខ្វៀចវៀចទៅនោះដក ជាដាច់ខាត ។

សូមប្រើម៉ាស៊ីនអង្គុលីលេខ ឬក៏ឯកសារដែលធ្វើសំបុត្រនេះ ។អ្នកត្រូវសរសេរឱ្យល្អ ហើយឱ្យបានត្រឹមត្រូវតាមក្បួន ។ ចូរបញ្ចៀសពីការផ្សាយ ដែលនាំឱ្យអ្នកសរសេរសំបុត្រឆ្លើយនេះ។ ចូរអ្នករាប់ នូវវិជ្ជាជីវៈពីរដែលអ្នកយល់ថាអាចជួយអ្នកឱ្យបានការងារនេះ ។ចូរបញ្ជាក់ក្នុងសំបុត្រនូវលេខទូរស័ព្ទអ្នក ហើយសុំឱ្យអ្នកអានសំបុត្រហៅទៅធ្វើសំភាស ។

បើអ្នកធ្វើសំបុត្រទូទៅ ផ្ញើទៅក្រុមហ៊ុនដែលមិនបានចុះផ្សាយរកអ្នកធ្វើការ ចូរសរសេរតាមក្បួនខាងដើមដូចគ្នា ហើយនិយាយពីការងារដែលអ្នករក ។

អ្នកត្រូវផ្ញើពាក្យទៅឈ្មោះមនុស្សដែលទទួលខុសត្រូវក្នុងការជួលអ្នកធ្វើការ ។ ចូរទូរស័ព្ទសួររកអ្នកដែលមានតំណែងក្នុងការជួលមនុស្ស សុំឱ្យគេប្រាប់ឈ្មោះ និងឋានន្តរសក្តិអ្នកនោះ ។ ទោះបីអ្នកអាចផ្ញើជាមួយនឹងជីវប្រវត្តិអ្នក ប៉ុន្តែអ្នកត្រូវតែធ្វើសំបុត្រអ្នកដោយប្រើម៉ាស៊ីនអង្គុលីលេខ កុំសរសេរដោយដៃឱ្យសោះ។ បើអ្នកសរសេរដោយដៃ អ្នកទទួលអាចបោះចោលក្នុងធុងសំរាមព្រោះគេពិបាកអាន ។
គំរូសំបុត្រសុំការងារនៅក្នុងនេះគឺជាមគ្គុទេស ចូរកុំចំលងសំបុត្រនេះ ។



## គំរូពាក្យសុំការងារថ្មី

បន ឡូ
១២ វិថី ខេម៉ន
គុកស្ទ្រីត អុនតារីយោ
LOC 1KO

ថ្ងៃទី ២៧ ខែមិនា ១៩៨១

អ្នកស្រី ហេទ្រិន ស្ត្រេន អនុរក្ស
ក្រុមហ៊ុន ប្រអប់ក្រដាស
៥០០ ផ្លូវ វុលស្វិង
អូស្វា អុនតារីយោ
L1G 2W2

សូមជំរាបមកអ្នកស្រី ស្ត្រេន :

សំបុត្រនេះឆ្លើយនឹងការផ្សាយរបស់អ្នកចុះក្នុងកាសែត Oshawa Times ក្រោមចំណងជើងថា "ជំនួយស្មៀន" ។

ខ្ញុំជានិស្សិតឆ្នាំទី១៣ នៅវិទ្យាល័យ គុកស្ទ្រីត ។ ខ្ញុំបង់ថ្ងៃ ការរៀនពេញពេលពីថ្ងៃទី៣១ ឧសភា ទៅថ្ងៃទី ១ កញ្ញា ។

ពេលរដូវក្តៅឆ្នាំ ១៩៨០ ខ្ញុំធ្វើការខ្លួនឯង ខាងលាងសំអាត កញ្ចក់ និងបង្អួច ។ ខ្ញុំជឿថា ការពិសោធន៍ដែលខ្ញុំបានមកពី ការទាក់ទងនឹងភ្ញៀវ និងការទទួលខុសត្រូវក្នុងកិច្ចការនេះ ជាការត្រូវការរបស់ក្រុមហ៊ុនអ្នក ។

ខ្ញុំផ្ញើភ្ជាប់មកជាមួយនេះនូវជីវប្រវត្តិរបស់ខ្ញុំ ហើយជាពិសេស ទៅទៀតសុំជួបនិងអ្នកដើម្បីសន្ទនាផ្ទាល់ ។ សូមអ្នកមេត្តា ទូរស័ព្ទមកខ្ញុំតាមការគួរដើម្បីរៀបចំធ្វើសំភាស ។

ខ្ញុំរង់ចាំចំលើយរបស់អ្នក ។

សូមអ្នកទទួលនូវសេចក្តីស្មោះត្រង់ពីខ្ញុំ
ហត្ថលេខា បន ឡូ
ទូរស័ព្ទ ៨៥២ ៨៥០១



## ដោតនីយទៅពេលមានសំភាស

ពេលសំភាសអ្នកមកដល់ហើយ ។ អ្នកអាចឃុំឃាំងការខ្វះការពិសោធ និងការខ្វះការបិនប្រសប់ ដោយបង្ហាញខ្លួនអ្នករបៀបណាឲ្យគេដឹងថាអ្នកអាចជាបុគ្គលមានជំនឿ ។

ចូរអ្នករៀបចំខ្លួនឲ្យបានប្រសើរ ។ តាមធម្មតា នយោជកច្រើនសំរេចក្នុង ១០ វិនាទីដំបូងពីការជួលអ្នកឬមិនជួល ។ អ្នកត្រូវតែស្លូតបាត កុំក្រខ្វក់ ហើយរក្សាភាពធម្មតា ។ ចូរកុំស្លៀកពាក់ឆើតឆាយពេក ឬតែងខ្លួន ឬលាបទឹកអប់ធ្វើលក់ ដែលធ្វើឲ្យអ្នកសំភាសបែកស្មារតីចេញពីការស្តាប់អ្នកនិយាយ ។ ចូរកុំបន្ថយជំនឿអ្នកដោយស្លៀកពាក់អន់ពេក។ បើអ្នកស្លៀកពាក់ខោអាវហ្មងៗ ទៅជួបគេ នោះមានន័យថា ខ្ញុំមិនយកចិត្តទុកដាក់និងបុណ្យស័ក្តិអ្នកប៉ុន្មានទេ បានជាខ្ញុំមិនស្លៀកពាក់ស្លូតបាត ។

ចូរចាំថា សំលៀកបំពាក់អ្នកមានជំនឿដូចគ្នានិងជីវប្រវត្តិអ្នក ។

ចូរទៅជួបគេឲ្យទាន់ពេលវេលា ។ សូមរកផ្លូវមុននិងទៅ ហើយបំរុងឈ្នួលធ្វើដំណើរទៅមក ។

សូមស៊ើបសួរតើអង្គការអ្វី មុននិងអ្នកទៅជួបនិងគេ ។ បើមិនជាអ្នកមានការភ្លាត់ស្នៀតក្នុងការធ្វើសន្ទនា និងសួរអំពីបញ្ហាដែលទាក់ទងនិងក្រុមហ៊ុន នោះអ្នកនិងធ្វើឲ្យរិតតែមានការចាប់អារម្មណ៍ទៅទៀត ។បណ្ណាល័យនៅកន្លែងអ្នកអាចមានពត៌មានពីក្រុមហ៊ុនធំៗ ។ ចូរអ្នកសាកសួរអ្នកដែលអ្នកស្គាល់អំពីក្រុមហ៊ុនតូចៗ ។

ពេលអ្នកទៅដល់កន្លែងធ្វើសំភាស ចូរសួររកឈ្មោះនិងអ្នកដែលអ្នកជួបអ្នក ។ ការចាប់អារម្មណ៍របស់អ្នកទទួលភ្ញៀវចំពោះអាចជាកត្តាមួយសំរេចក្នុងការជួល ឬមិនជួលអ្នក ។

ពេលអ្នកជួបនិងអ្នកត្រូវធ្វើសំភាសអ្នក ចូរនិយាយទៅរកអ្នកនោះ ដោយហៅឈ្មោះ ។ត្រូវនិយាយថា "អរគុណ លោក --------ដែលបានឲ្យខ្ញុំមកជួប" រួចចាប់ដៃគាត់ដោយមធ្យម ។ ចូរនិយាយឡើងមុនតែឲ្យចំនៅពេលធ្វើសំភាស ដែលជាសញ្ញាឲ្យដឹងថាអ្នកស្មោះត្រង់ និងចង់ធ្វើការ ។

ចូររៀបចំឆ្លើយនិងសំនួរ "ចូរនិយាយពីខ្លួនអ្នកប្រាប់ខ្ញុំ" សំនួរនេះគឺថាជាសំនួរ មួយដែលអ្នកធ្វើសំភាសប្រើសួរគ្រប់អ្នករកការងារធ្វើ មានន័យថា "ហេតុអ្វីបានជាខ្ញុំត្រូវជួលអ្នក" ចូរយកជីវប្រវត្តិអ្នកជាប់ជាមួយ ហើយរំលឹកវាឲ្យញយៗទៅអ្នកធ្វើសំភាស ។ អ្នកត្រូវធ្វើឲ្យអ្នកសំភាសចាប់អារម្មណ៍ថាអ្នកចង់ធ្វើការខ្លាំង សប្បាយរីករាយ ហើយនិងជួយបង្កើនសេចក្តីចំរើនដែលអាចធ្វើឲ្យក្រុមហ៊ុនមានភាពរុងរឿង ។

ពេលធ្វើសំភាសរួច ចូរអរគុណនិងអ្នកសួរម្តងទៀតដោយបានបំណាយពេលជួបនិងអ្នក ហើយចាប់ដៃគា ។ពិតមែនតែអ្នកមិនបានការងារភ្លាមក៏ដោយ ក៏ក្រោយពេលណា អ្នកអាចមានដោយអ្នកបានទុកការចាប់អារម្មណ៍ល្អ ។ ត្រង់នេះមានន័យថា គេនិងជួលអ្នក ពេលណាមានកន្លែងទំនេរ ។

ចូរសំរេចថា តើការផ្ញើសំបុត្រអរគុណមានប្រយោជន៍ដល់អ្នកឬទេ ។ បើអ្នកយល់ឃើញថា និងបានផលដល់អ្នក ចូរសរសេរសំបុត្រមួយអរគុណ ដល់អ្នកសំភាសអ្នក នៅពេលទៅដល់ផ្ទះ ។ សំបុត្រអរគុណត្រូវខ្លី ហើយសរសេរដោយដៃ ។ចូរអរគុណអ្នកសំភាសម្តងទៀត ដែលបើកឱកាសឲ្យអ្នកសុំការងារ ។ សូម

បញ្ញាវិជ្ជាជីវៈ និងសមត្ថភាពរបស់អ្នក ។ ទីបញ្ចប់នៃសំបុត្រ ចូរសរសេរថា អ្នកសង្ឃឹមថានឹងបានដំណឹងក្នុងរយៈពេលយ៉ាងខ្លី ។ សូមផ្ញើសំបុត្រនេះភ្លាម ។

ចូរកត់ទីកន្លែងដែលអ្នកបានទៅសំភាស និងកត់ពីការដែលគេសំភាសអ្នក ។ ចូរកត់កាលបរិច្ឆេទនៃសំបុត្រពាក្យការងារធ្វើ ។ ការកត់នេះជាពត៌មាន ប្រយោជន៍សំរាប់ឲ្យដឹងថា កន្លែងណាខ្លះដែលអ្នកបានទៅ អ្នកណាខ្លះដែលអ្នកបានជួប និងអ្នកណាខ្លះដែលអ្នកត្រូវជួបម្តងទៀត ។

ពិនិត្យកិច្ចការដែលត្រូវធ្វើ :

- ចូរអានសៀវភៅមគ្គុទេសក៍នេះពីដើមដល់ចប់
- ឲ្យដឹងទាំងខ្លួនឯងនិងផ្សារការងារ
- សំរេចថាតើអ្នកចង់ធ្វើការងារអ្វី
- យកប័ណ្ណការងារទៅជាមួយនៅពេលទៅរកការងារធ្វើ និងពេលធ្វើសំភាស
- វាយអត្ថលេខជីវប្រវត្តិ និងផ្តិតឲ្យច្រើនសន្លឹក
- ប្រាប់មិត្តភ័ក្រនិងបងប្អូនឲ្យដឹងថាអ្នកកំពុងរកការងារធ្វើ
- អានការផ្សាយពីការងារនៅក្នុងកាសែត
- ផ្ញើសំបុត្រសុំធ្វើការទៅកន្លែងផ្សាយការងារ និងទៅក្រុមហ៊ុនដែលមិនផ្សាយពីការងារ
- ទៅក្រសួងការងារកាណាដា រកមើលការងារដែលបិទផ្សាយ
- ទូរស័ព្ទទៅកន្លែងដែលអ្នកចង់ធ្វើ ដើម្បីសុំឲ្យគេធ្វើសំភាសនៅកន្លែងគេ បើយល់ថាជាការល្អ សូមប្រាប់គេឲ្យដឹងថាអ្នកចង់ធ្វើការឲ្យគេ
- រៀបចំខ្លួនអ្នកដើម្បីធ្វើសំភាស
- ដឹងពីក្រុមហ៊ុនឬអង្គការណាដែលអ្នកត្រូវទៅធ្វើសំភាស
- តាំងចិត្តគិតពីការដែលគេមិនរើសយកអ្នក
- រក្សាបញ្ជីការងារដែលអ្នករក
- តស៊ូ



## ការត្រូវបំពេញ

សូមសរសើរ អ្នកបានការងារហើយ !!

ឥឡូវអ្នកត្រូវខំធ្វើការ ដើម្បីរក្សាការងារនេះ ហើយ ធ្វើឲ្យការនេះផ្ដល់ប្រយោជន៍ឲ្យអ្នក ។

ការត្រៀមខ្លួនមានប្រយោជន៍ណាស់ ពេលណាអ្នកចាប់ផ្ដើមទៅធ្វើការ ឬអ្នកដូរមុខការមិនពេញពេលទៅពេញពេលវិញ ។ បើអ្នកគាំចតិតទុកជាមុននូវអ្វីដែលត្រូវកើតមានចំពោះរូបអ្នក ហើយអ្នកធ្វើតាមបន្ទាត់មគ្គុទេសន៍ដូចខាងក្រោម ការត្រៀមខ្លួននេះនឹងទៅជាការងាយ :

ទទួលការខុសត្រូវ :

ចូរដឹងឲ្យច្បាស់ថាអ្នកអាចការងារដែលគេជួលអ្នកឲ្យធ្វើបាន ។ ចូរយល់ឲ្យច្បាស់ថាអ្វីដែលនិយោជកចង់បាន ។ ចូរកុំញញើតនិងសួរការណាដែលអ្នកមិនដឹង ។សូមធ្វើការអ្នកដោយយកចិត្តទុកដាក់ និងឲ្យបានការ ។ការបំពេញករណីយកិច្ចជាការកង្វល់របស់អ្នក ។

ទៀងទាត់ពេល និងនៅទីកន្លែងធ្វើការ :

ចូរធ្វើរបៀបណាអោយបានទៅដល់ទីកន្លែងធ្វើការទាន់ពេលវេលា ហើយនៅកន្លែងនោះទល់ពេលចេញធ្វើការ ។ការលាឈប់ទៀតទុកអ្នកជាទីពុំនឹង ការដែលអ្នកមិននៅនឹងកន្លែង ឬអ្នកទៅយឺតជាការមិនល្អទេ ។ ការបាត់ខ្លួនញយៗពីកន្លែងធ្វើការ ជាហេតុធ្វើអោយនិយោជកនឹងថាមិនទាន់ចាស់ចិត្តចាស់គំនិត ខ្វះការទទួលខុសត្រូវ ហើយមិនអាចការពារការងាររបស់អ្នកបាន ។ បើអ្នកទៅធ្វើការមិនបានអ្នកត្រូវទូរស័ព្ទប្រាប់មេភ្លម ។ បើអ្នកត្រូវអោយគ្រូពេទ្យ ឬពេទ្យធ្មេញពិនិត្យ ចូរណាត់ជួបនឹងគ្រូពេទ្យនៅពេលក្រោយថ្ងៃត្រង់ ហើយប្រាប់អ្នកធ្វើការជាមួយអោយដឹងកន្លែងដែលអ្នកទៅ ។

ធ្វើការអោយគ្រប់ ១០០ ភាគរយ :

ចូរកុំបណ្តោយអោយជីវិតក្នុងសង្គមរំខានដល់ការងារអ្នក ។
ចូរសំរាកអោយបានច្រើន ដើម្បីកុំអោយងងុយនៅពេលធ្វើការ ។
ចូរកុំប្រើទូរស័ព្ទច្រើនពេក ។

ស្លៀកពាក់អោយស្អាតបាត :

ការស្លៀកពាក់មានរបៀបខុសៗគ្នាពីកន្លែងមួយទៅកន្លែងមួយ ។ចូរដឹងថាក្នុងការស្លៀកពាក់នេះ អ្នកអាចបញ្ចេញនិមិត្តរូបដែលចាំងឆ្លុះលើរូបអ្នក និងនិយោជកអ្នក ។

អត់អោន និងអធ្យាស្រ័យ :

ការធ្វើការជាមួយមនុស្សដែលតែងតែជួបការពិបាកជាញឹកញាប់ ។ ចូរកុំលន់រឿងតូចតាច ហើយបង្កើតជារឿងធំ ។ ចូរមើលឃើញភាពតាមទស្សនៈអ្នកធ្វើការជាមួយ និងអ្នកត្រួតត្រា ។ ត្រូវទទួលការទិតៀន ហើយយកយោបល់អ្នកដទៃ ដើម្បីកែកំហុសអ្នកអោយបានត្រឹមត្រូវ ។ ចូរចាំថាអ្នកអ្នកជាបុគ្គលមួយរូបនៃមនុស្សមួយក្រុម ហើយជោគជ័យនៃបុគ្គលមួយរូបបានមកពីការគាំទ្រអស់គ្នា ។

បញ្ចេញការខ្ពើមឆ្អើម :

លំដាប់ណាអ្នកយល់ច្បាស់ថាអ្នកសារភាពការខុស លំដាប់នោះមានន័យថា អ្នកបានធ្វើការងារ ហើយនិងរកផ្លូវធ្វើឱ្យការងារនោះបានចំរើន ។ចូរនិយាយចេញ ហើយយល់ឃើញថា ហេតុអ្វីអ្នកល្អ ហើយនិយាយប្រាប់អ្នកគ្រួសារ ។ កុំបណ្តោយឱ្យការងារនោះ ទៅជាការងារធម្មតា ហើយនឹងដដែលៗ ។ ចូរយកចិត្តទុកដាក់យ៉ាងសកម្មក្នុងការងាររបស់អ្នក ។ កុំញញើតធ្វើការរើសម៉ោង ឬជួយធ្វើការដែលជាមិនមែនជាមុខការរបស់អ្នក ។ ការបញ្ចេញការខ្ពើមឆ្អើម និងការធ្វើញត្តិប្រតិបត្តិការជាផ្លូវល្អសំរាប់ទទួលបុណ្យស័ក្តិ ។ ប៉ុន្តែបើអ្នកមិនបានទទួលវិញ ចូរដឹងថា មានគេធ្វើការមុនអ្នក ឬត្រូវគេទទួលមុនតាមបញ្ជីវេន ឬវេនគេល្អជាងអ្នក ។

ចន្លោះការសាកល្បង :

ចូរកសាងខ្លួនអ្នកឱ្យរឹតតែមានតម្លៃ ។ ចុះឈ្មោះទៅរៀនពេលយប់ បង្កើនការប៉ិនប្រសប់ដែលក្រុមហ៊ុនអ្នកបានបង្រៀនៗ មានករណីខ្លះ និយោជកចេញថ្លៃសាលាពេញ ឬជួយចេញខ្លះឱ្យអ្នក ។ ត្រូវឆ្លៀតយកប្រយោជន៍នេះ ។

ដោះស្រាយភាពតប់ប្រមល់ :

ភាពតប់ប្រមល់លើផ្លូវចិត្តនៅពេលធ្វើការ ទៅលើមនុស្សម្នាក់ៗមានការប្លែកពីគ្នា ។ កន្លែងខ្លះគេធ្វើការស្រួល ហើយគ្មានការតឹងចិត្ត ។កន្លែងខ្លះទៀត មានការលំបាកលើកម្លាំងកាយ និងផ្លូវចិត្ត ។ បើសិនជាមានភាពចង្អៀតចិត្តក្នុងការប្រកបការងារនេះ អ្នកត្រូវតែរកផ្លូវដោះស្រាយជាបន្ទាន់ ។ ពេលបាយថ្ងៃត្រង់ជាឱកាសមួយដ៏ល្អដើម្បីដើរ ឬហែលទឹក ឬលេងបាល់ ជាដើម ។ អ្នកត្រូវសំរាកនៅពេលយប់ ។ អ្នកគួរអានសៀវភៅ មើលកុន ស្តាប់ភ្លេង ហើយងូតទឹកក្តៅ ។ ចំណាយពេលពិនិត្យបញ្ហា ហើយរកផ្លូវបន្ធូរការខ្វល់ខ្វាយ និងការដាក់គំនិតទៅជាកម្លាំងកាយវិញ ។

ក្រោយពីនេះ បើអ្នកនៅតែចាប់អារម្មណ៍ថា ការចង្អៀតចិត្តនៅតែមិនអាចដោះស្រាយបាន សូមអ្នករកមិត្តភក្ដិ បងប្អូន ឬទីប្រឹក្សាការងារ ។ ត្រូវនិយាយដំណើររឿងប្រាប់គេ ហើយសុំជំនួយពីគេ ។ ទីបញ្ចប់ បើអ្នកសំរេចថា ចំណោទនេះអ្នកមិនអាចដោះស្រាយបាន អ្នកត្រូវរកការងារថ្មីមួយទៀត ។ អ្នកត្រូវកែតម្រូវជីវប្រវត្តិអ្នក ហើយរកការងារណាដែលពេញចិត្តអ្នក ។

ឈប់ធ្វើការ :

ទោះបីអ្នកមានមូលហេតុយ៉ាងណាក៏ដោយក្នុងការឈប់នេះ ចូរអ្នកឲ្យដំណឹងទៅនាយោជកអ្នកពីរអាទិត្យជាមុន ។ អ្នកត្រូវបង្ហើយការងារអ្នក ហើយប្រាប់មិត្តភក្ដិដែលធ្វើការជាមួយ ។ ទុកអាស័យដ្ឋាន និងលេខទូរស័ព្ទអ្នកឲ្យគេ ។ មុននឹងឈប់អ្នកគួរសុំសំបុត្រយោងពីនាយោជកអ្នក ព្រោះសំបុត្រនេះនឹងអាចមានប្រយោជន៍នៅពេលរកការងារថ្មី ។

ការងារនិមួយៗ ជាកាលៈទេសៈសំខាន់ក្នុងបណ្ដាវិវត្តិនៃមុខរបររបស់អ្នក ។ ការងារនិមួយៗ សុទ្ធតែផ្ដល់នូវការចេះដឹង និងការពិសោធ ។ អ្នកត្រូវរក្សាគោលដៅ ហើយនិងទទួលស្គាល់នូវអ្វីៗដែលអ្នកបានរៀន និងបានដុះដាល ។ ត្រូវអនុវត្តអ្វីៗដែលអ្នកបានរៀន ដើម្បីឲ្យបានដល់ទីដៅ នៃការងារដែលដែលអ្នកបានប្រាថ្នា ។



## ការបង្កើតការងារ

ការធ្វើទៅឲ្យដោយខ្លួនឯង :

កាលណាអ្នករកការងារ អ្នកគួរគិតតែពីរឿងការរកស៊ីផ្ទាល់ខ្លួន ។ ប៉ុន្តែការបង្កើតនេះមានការពិបាក និងគ្រោះថ្នាក់ ជាជាងធ្វើការឲ្យគេ រង្វាន់និងការគាប់ចិត្តអាចមាន សភាពច្រើនជាងឈ្នួលគេ ។

ដើម្បីធ្វើជាម្ចាស់ការ អ្នកត្រូវការការតាំងចិត្ត ការប៉ិនប្រសប់ក្នុងការចាត់ចែង ត្រួតត្រា និងគំនិតល្អ ។ ចូរកុំសាកល្បងនឹងរឿងនោះ ៖ បើអ្នកមានតែលក្ខណៈមួយ ឬពីរ ក្នុងលក្ខណៈទាំងបីនេះ ដែលលក្ខណៈចាំបាច់ធ្វើឲ្យអ្នកទទួលជោគជ័យ ។

ឧទាហរណ៍ស្តីពីអ្នកចង់ធ្វើការដោយខ្លួនអ្នកច្រើនជាងធ្វើការឲ្យគេ ហើយចង់ចាត់ការការងារដោយខ្លួនឯង អ្នកត្រូវគិតឲ្យបានច្បាស់ ។ តើអ្នកត្រូវរកស៊ីអ្វី ។

ចូរធ្វើបញ្ជីពីកោសល្យ ឬលក្ខណសម្បត្តិរបស់អ្នក ហើយសង្កេតមើលតើ

អ្នកអាចបង្កើតផលិតផលទេ ឬហិតប្រយោជន៍អ្វីដែលអ្នកផង ត្រូវការឬទេ ។

បើអ្នកពូកែខាងចំណោទ ឬភាសាអង់គ្លេស អ្នកអាចធ្វើជាអ្នកព្យាឡាយឯកជន ។ បើអ្នកជាកម្មករ អ្នកអាចធ្វើជាងឈើ អ្នកសំអាតបង្គន់ អ្នកលាងកញ្ចក់បង្អួច ឬអ្នកយាមផ្ទះ ។ បើអ្នកសប្បាយនិងនៅជាមួយក្មេងតូចៗ អ្នកអាចមើលទារក ឬមើលក្មេងតូចៗ បើអ្នកចូលចិត្តសត្វ អ្នកអាចបណ្តើរ ឲ្យចំណី ថែរក្សា និងបង្ហាត់ឆ្កែ ។ បើអ្នកចូលចិត្តធ្វើការមេកានិក អ្នកអាចដេរ ជួតផ្ទះ ចាំផ្ទះ ឬរ៉ាយអម្ពិលនៅឈើ ។ លទ្ធភាពមានទំនុកពុំស្គាល់ ហើយពួកវានឹងចាប់ការឡើង ។

ជំហានបន្ទាប់របស់អ្នកគឺពិនិត្យផ្សារដែលនៅជិតខាងអ្នក ។

សាកល្បង ហើយនិងសង្កេតមើលថា តើ មានអ្នកត្រូវការ ផលិតផល និងហិតប្រយោជន៍ របស់អ្នកឬទេ តើមានអ្នក ប្រកួតប្រជែងឬទេ រួចហើយអ្នកសំរេចថា បើកឬមិនបើក នៅកន្លែងនោះ ។

លុះសំរេចពីគ្រោងការនិងទីកន្លែងហើយ អ្នកត្រូវពិនិត្យ និងសាកល្បងពីខាងផ្លូវច្បាប់ក្រែងគេមិនអនុញ្ញាតិឲ្យ បើក ។ ឧទាហរណ៍ ដូចជាអ្នកចង់បើកហាងលក់ម្ហូប អ្នក ត្រូវទៅសួរក្រសួងសុខាភិបាលដែលនៅសង្កាត់នោះ ។ បើអ្នកចង់លក់គ្រឿងចំរាក់ ឬរបស់ធ្វើពីដែក អ្នកត្រូវ ពិនិត្យមើលតើត្រូវមានច្បាប់អនុញ្ញាតិឲ្យលក់ និងលេខ អាករឬទេ ។ អ្នកអាចរកពត៌មាននេះ នៅការិយា ល័យក្រុមខេត្ត ក្នុងសង្កាត់អ្នក ឬនៅមន្ទីរពាណិជ្ជកម្ម ។ ចូរដឹងថា ជាការទទួលខុសត្រូវរបស់អ្នកក្នុងការដឹងច្បាប់ មុននឹងអ្នកចាប់បើកហាង ។

បន្ទាប់ពីអ្នកពិនិត្យរួចហើយ អ្នកត្រូវគិតអំពីការចំណាយ ប្រាក់ក្នុងការទិញឥវ៉ាន់ និងប្រដាប់ប្រដារ ។ អ្នកត្រូវ សំរេចអំពីការដាក់តំលៃលក់ផលិតផល និងហិតប្រយោជន៍ ។

ចូរកុំចំណាយដើមទុនច្រើនពេក ។ កុំទិញម៉ាស៊ីនកាត់ស្មៅថ្មី អគ្គីសនី ឬម៉ាស៊ីនដេរ ។ ចូរសាកខ្ចីរបស់ទាំងនេះពីមិត្តភ័ក្រ ឬបងប្អូនៗបើខ្ចីមិនបាន អ្នកអាចជួលប្រដាប់ទាំងប៉ុណ្ណាដែលត្រូវការ ។ អ្នកត្រូវគិតចំណាយដើមទុនតែលើបរិក្ខារណាដែលបានបំរើច្រើន ។ ចូរជៀសវាងគ្រោះថ្នាក់បំណុល ។ ទីបញ្ចប់ គិតគូរកប្រាក់ត្រូវទៀតវាថា កុំឱ្យជំពាក់គេ និងកុំឱ្យខាត ។

ការខ្ចីប្រាក់ :

បើអ្នកដឹងថា អ្នកមិនអាចចាប់ផ្តើមរកស៊ី ដោយមិនខ្ចីលុយគេ ចូរអ្នករកខ្ចីប្រាក់សំរាប់និស្សិតក្នុងការចាប់ផ្តើមមុខរបររដូវក្តៅ ។ កម្មវិធីដើមទុនផ្សងព្រេងដែលជួយដោយរដ្ឋាភិបាលខេត្តអុនតារីយ៉ោ អាចឱ្យខ្ចីរហូតដល់ ១ 000 ដុល្លារ ដោយគ្មានការប្រាក់ ដើម្បីរៀបចំការងាររដូវក្តៅ ។ ដើម្បីខ្ចីបាន អ្នកត្រូវមានអាយុយ៉ាងតិច ១៦ ឆ្នាំហើយត្រូវត្រឡប់ទៅរៀនពេញម៉ោងនៅពេលបើកឆ្នាំសិក្សា ។ កម្មវិធីនេះចូលក្នុងកម្មវិធីការពិសោធ ឆ្នាំ ១៩៨១ នៃលេខាធិការយុវជនខេត្តអុនតារីយ៉ោ ។ អ្នកអាចរកព័ត៌មានបន្ថែម ដោយសរសេរទៅ :

PROGRAM MANAGER, Student Venture
Capital, Ontario Youth Secretariat,
Queen's Park, Toronto,Ontario
M7A 1Z1

អ្នកអាចសួរទីប្រឹក្សាមុខរបរថា តើអ្នកមានលទ្ធភាពនិងខ្ចី ឬសុំជំនួយពីអង្គការណាទៀតបានទេ ។

អ្នកអាចនិយាយនឹងអ្នកការងាររបស់ខាងខ្ចីប្រាក់ ឬចាងហ្វាងខាងឱ្យខ្ចីប្រាក់នៅធនាគារ ឬនៅក្រុមហ៊ុនបងការប្រាក់ៗ អ្នកទាំងនោះចង់ដឹងពីផលិតផល និងហិតប្រយោជន៍ ដែលអ្នកអាចផ្តល់ និងចង់ដឹងពីតម្លៃលក់ និងកំរៃដែលនឹងបាន ។

បើអ្នកជួបការពិបាកក្នុងការរកស៊ី ឬជួបនឹងខាតទុន សមាជិកក្រុមរបស់អ្នក ត្រូវតែជួយខ្ចីប្រាក់ជាមួយគ្នា ។ ត្រង់នេះមានន័យថា គេជាអ្នកតាមសងប្រាក់ជំនួសអ្នក បើអ្នកមិនអាចសងបានក្នុងករណីណាក៏ដោយ ។

ពេលនោះអ្នកសងប្រាក់ដើម អ្នកត្រូវសងការប្រាក់ដែរ ។ ពេលដែលអ្នកខ្ចីប្រាក់ គេនឹងប្រាប់អ្នកពីចំនួនការប្រាក់ដែលអ្នកត្រូវសង និងប្រាក់ដើមជាដុល្លា និងរៀល ។

ជំហានមួយទៀត គឺការសរសេរកត់ត្រាចំណូលចំណាយ និងផលប្រយោជន៍ ។ ចូរធ្វើការប្រៀបប្រដៅ ដើមតម្លៃនៅផ្សារ ពាក្យពីតម្លៃដែលគេចង់ទិញចំពោះតម្លៃដែលអ្នកចង់លក់ ។ ដើម្បីតម្លៃអ្នកដាក់ឡើង ។ បើអ្នកបញ្ចុះតម្លៃរបស់អ្នក ចូរកុំសារកខ្លួនឯង ដោយយកថោកពេកតាមកម្រៃ ។



ការផ្សាយពីខ្លួនអ្នក :

ពេលនេះជាពេលដែលត្រូវធ្វើឲ្យគេដឹងថាអ្នកមានអ្វីល្អដែលគេត្រូវការ ។ ការផ្សាយពីខ្លួនឯង មានរបៀបច្រើនយ៉ាង ប៉ុន្តែផ្សព្វផ្សាយល្អគឺពាក្យមនុស្ស ។ ធ្វើការងារល្អឲ្យគេ គេនឹងនិយាយពីអ្នកប្រាប់អ្នកដទៃ ។ ធ្វើការងារមិនល្អឲ្យគេ ដំណឹងអាក្រក់ក៏សាយភាយចេញ រួចហើយ ។ ចូរអ្នករក្សាកេរ្តិ៍ឈ្មោះឲ្យបានល្អ ។ បើកេរ្តិ៍អាក្រក់ អ្នកមិនអាចរកការងារបានទេ ។

ចំណុចផ្សាយ:

ចូររកកន្លែងបោះពុម្ព ឬហាងបោះពុម្ពការដែលនៅតាមសង្កាត់អ្នក សួរមើលថាតើថ្លៃរៀបចំ និងបោះពុម្ពលិខិតផ្សាយចំនួន ១០០ សន្លឹកថ្លៃប៉ុន្មាន ។ អ្នកអាចចែកប័ណ្ណផ្សាយតាមផ្ទះ ឬតាមគ្រួសារដែលប្រណិត ទៅអ្នកដែលអ្នកយល់ថាជាភ្ញៀវរបស់អ្នក ។

ម្យ៉ាងទៀត អ្នកអាចផ្សាយតាមការដែលដើរទៅតាមផ្ទះអ្នក ។ បើការរកស៊ីរបស់អ្នកទៅរួច អ្នកអាចទាក់

ទងនិងកាសែត ឬវិទ្យុតាមតំបន់អ្នកផ្សាយ ហើយកុំអៀនខ្មាស់និងទៅជួបអ្នកទាំងនេះ ។

ចុងក្រោយ ប៉ុន្តែមិនមែនជាទីបញ្ចប់ទេ ចូរកុំភ្លេចប្រើទូរស័ព្ទក្នុងការផ្សាយ ។ របៀបនេះមិនអស់លុយទេ ដើម្បីឲ្យគេដឹងពីការរកស៊ីរបស់អ្នក ហើយជាផ្លូវងាយ និងបានចំណេញយ៉ាងភ្លាមៗ ។

ការធានារ៉ាប់រង :

ការដែលអ្នកទទួលខុសត្រូវក្នុងការដឹងច្បាប់ពីការរកស៊ីរបស់អ្នក ក៏ដូចគ្នានឹងការដែលអ្នកត្រូវទទួលខុសត្រូវក្នុងការពារខ្លួនអ្នក និងភ្ញៀវអ្នកដោយមានការធានារ៉ាប់រង បើសិនជាច្បាប់តំរូវឲ្យមាន ។ ការទទួលខុសត្រូវរបស់អ្នកមានទំហំទៅតាមការងាររបស់អ្នក ។ ឧទាហរណ៍ បើអ្នកជាអ្នកវាយអង្គុលីលេខធ្វើសេចក្តីរាយការណ៍ អ្នកមិនត្រូវការការធានារ៉ាប់រងទេ ។ តែបើអ្នកបើករថយន្តដឹកក្មេង ឬចាស់ជរាទៅទីក្រុង អ្នកត្រូវបង់ប្រាក់ប្រើក្នុងការធានារ៉ាប់រង ។

អ្នកត្រូវទៅជួបនិងភ្នាក់ងារធានារ៉ាប់រង ហើយសួរពត៌មានឲ្យបានល្អិតល្អន់ ។ ការធានារ៉ាប់រងក្នុងការរកស៊ីខុសគ្នាស្រឡះពីការធានារ៉ាប់រងផ្ទះ ឬរថយន្ត ។ នៅពេលនោះ អ្នកត្រូវដឹងថាអ្វីដែលអ្នកត្រូវការដើម្បីការពារខ្លួនអ្នក និងភ្ញៀវរបស់អ្នក ។

កិច្ចសន្យា :

កិច្ចសន្យាជាសេចក្តីព្រមជាសំដី ឬជាលិខិតដែលរៀបរាប់ពីការងារដែលអ្នកសន្យាថាធ្វើ និងតម្លៃដែលភ្ញៀវអ្នកសន្យាថាចេញឲ្យ ។

កិច្ចសន្យាជាសំដីទុកជាបានការ ប៉ុន្តែមានការពិបាកនឹងបង្ហាញតាងនៅពេលដែលកើតរឿង ។ កិច្ចសន្យាជាលិខិតមិនត្រឹមតែមានសេចក្តីច្បាស់លាស់ទេ ថែមទាំងទុកជាភស្តុតាងនៅពេលដែលអ្នកត្រូវការ ។

ការធ្វើកិច្ចសន្យាជាលិខិតជាការល្អណាស់ ព្រោះកិច្ចសន្យានេះការពារអ្នកដោយបញ្ជាក់ឱ្យដឹងថាអ្នកណានឹងទទួលការខុសត្រូវក្នុងការផ្ដល់សំភារៈ និងបរិក្ខា ។ កិច្ចសន្យានេះការពារភ្ញៀវអ្នក ដោយសំរាប់វងតថ្លៃនៃការងារ មុនពេលចាប់ធ្វើការ ។

វាយអង្គុលីលេខកិច្ចសន្យាជាពីរច្បាប់ មួយច្បាប់ឱ្យទៅភ្ញៀវអ្នក មួយច្បាប់ទៀតត្រូវទុកជាឯកសារអ្នក ។ កិច្ចសន្យាត្រូវចុះកាលបរិច្ឆេទ សំរាប់ពីការងារ តម្លៃ និងឈ្មោះអ្នកជាប់ក្នុងកិច្ចសន្យា ។ គូរភាគីនៃកិច្ចសន្យាត្រូវចុះហត្ថលេខា ។ ចូរមើលកិច្ចសន្យាខាងក្រោមនេះ –

## គំរូកិច្ចសន្យា

ខែ តុលា ថ្ងៃ ទី ៣០ ឆ្នាំ១៩៨១

ឈ្មោះ ចន ឌូ ផ្ទះលេខ ៥៥ ផ្លូវមេរិល លិតប៊ូរី យល់ព្រមកាត់ស្មៅដោយម៉ាស៊ីន តម្រឹមគុម្ពឈើរបងផ្ទះ និងប្រមូលសំរាមឱ្យអ្នកស្រី ប្រោន ផ្ទះលេខ ១៥ ផ្លូវមេរិល លិតប៊ូរី រាល់ថ្ងៃសុក្រ ក្នុងកំឡុងខែ មិថុនា កក្កដា និងសីហា ឆ្នាំ ១៩៨១ ហើយនិងយកប្រាក់ឈ្នួលចំនួន ១០ ដុល្លារមួយដង ដែលត្រូវចេញរាល់អាទិត្យ ។ អ្នកស្រីប្រោនជាអ្នកផ្ដល់គ្រឿងសម្ភារៈ ។ បើភ្លៀងនៅថ្ងៃសុក្រ ចន ឌូ និងអ្នកស្រីប្រោន នឹងរើសថ្ងៃដោយព្រមព្រៀងគ្នា ។

ហត្ថលេខា

------

ចន ឌូ

------

អ្នកស្រីប្រោន



## ការទុកឯកសារ

អ្នកត្រូវកត់ត្រាឱ្យបានត្រឹមត្រូវនូវប្រាក់ចំណូល និងចំណាយ ។ របៀបនេះនឹងធ្វើឱ្យអ្នកដឹងថាចំណេញ ឬខាត ។

ចូរបើកគណនីសន្សំមួយនៅធនាគារ ។ កូនសៀវភៅធនាគារ Passbook និងសេចក្តីរាយការណ៍ប្រចាំខែដែលធនាគារផ្ញើមកនឹងជួយឱ្យអ្នកដឹងពីការរកស៊ីរបស់អ្នកថាតើចំណេញ ឬខាត ។

បើអ្នកចេះរៀបចំ ឬចាត់ចែងល្អ អ្នកនឹងដឹងថាបានជោគជ័យ ឬមិនបាន ។ បើអ្នកត្រូវការធ្វើសាកសួរប្រាក់ចំណូល បញ្ជីកត់ត្រានឹងមានស្លាកនៅជិតអ្នក ។

ការធ្វើឱ្យបានជោគជ័យ :

-ប្រឹងប្រែងធ្វើការឱ្យខ្លួនអ្នកច្រើនជាងធ្វើការឱ្យអ្នកក្រៅ ។
-មានការបិទប្រកាសថ្លៃលក់ដូរ ឬតាំងផលិតផល
-ពិនិត្យឱ្យបានត្រឹមត្រូវនូវតំបន់ដែលអ្នកចង់លក់ដូរ ឱ្យបានដឹងថាមានអ្នកទិញឬទេ ។

-សាកសួរនូវការិយាល័យក្រុមហ៊ុន ឬមន្ទីរពាណិជ្ជកម្ម ឬ មន្ទីរនាយកដ្ឋានជំនួញ ពីផ្លូវច្បាប់និងការងារមយាត់ ។

-ទិញបរិក្ខា និងគ្រឿងផ្គត់ផ្គង់ដោយតម្លៃថោកបំផុត

-ខ្ចីប្រាក់បើមានការចាំបាច់

-ផ្សាយ

-មានធានារ៉ាប់រងបើមានការត្រូវការ

-ធ្វើកិច្ចសន្យាជាលិខិត

-សន្យាថាធ្វើការនិយ័តរ លំដាប់ណាអ្នកអាចធ្វើនិយាយបាន ទាន់ពេល

-ត្រូវគួរសម និងទៀងទាត់ពេលវេលា ហើយនិងការពារ កេរ្តិ៍ឈ្មោះអ្នក

-រក្សាបញ្ជីចំណូល និងចំណាយអោយបានត្រឹមត្រូវ

-បើកគណនីយមួយនៅធនាគារ

-សួរដំបូន្មានពីគ្រប់មជ្ឈដ្ឋាន

ការពង្រីក:

បើសហគ្រាសតូចរបស់អ្នកបានល្អ ហើយអ្នកចង់ពង្រីកខ្លួន ទៅជាធំពេញលក្ខណៈ ចូរអ្នកពិនិត្យជាមួយក្រសួងនានា មន្ត្រី និងទីភ្នាក់ងារផ្សេងៗខាងក្រោមនេះ ដែលអាចជួយផ្តល់ ពត៌មានពីច្បាប់ស្តីពីការរកស៊ីរបស់អ្នក ហើយពន្យល់អ្នកពី គ្រោះថ្នាក់ដែលនាំឲ្យសហគ្រាសតូច ៧ ក្នុង ១០ ក្នុង រវាង ២៥ ឆ្នាំដំបូង :

-ក្រសួងឧស្សាហកម្ម និងទេសចរណ៍ : ចំពោះពត៌មានពី ការគ្រប់គ្រងនៃសហគ្រាសតូច

-ក្រសួងបរិភោគ និងការទាក់ទងខាងជំនួញ : ពត៌មាន ពីកម្មសិទ្ធិ ការរកស៊ីរួមគ្នា និងអង្គការសហគ្រាស

-ក្រសួងការងារខែត្រអុនតារីយោ : ទីចាត់ការសង ការខូចខាតនៃអ្នកធ្វើការ ការិយាល័យច្បាប់ការងារ និងក្រុមការងារសិទ្ធិមនុស្ស ផ្តល់ពត៌មានពីការជួយមនុស្ស

-ក្រសួងប្រាក់ចំណូលការណាដា : ចំពោះពត៌មានពីលេខ

និយោជិក ភាគរយប្រាក់ខែ ផែនការសោធនការណ៍ជា
និងការធានារ៉ាប់រងពេលឈប់ការធ្វើ

-កម្មវិធីផ្សេងៗនៅសហគ្រាសតូច និងកម្មវិធីជំនួយផ្លូវច្បាប់ :
ចូររកនៅមហាវិទ្យាល័យនៅក្នុងសង្កាត់ ដើម្បីមិនបង់
ថ្លៃ ឬបង់ថ្លៃថោក ។ បញ្ជីការិយាល័យកម្មវិធីទាំងនេះ
មាននៅក្នុងសៀវភៅទូរស័ព្ទក្រោមផ្នែក "រដ្ឋាភិបាល
ខេត្តអុនតារីយោ" ឬ "រដ្ឋាភិបាលកាណាដា"។

ហើយសូមចាំថា សៀវភៅទូរស័ព្ទនេះមានប្រយោជន៍
ដល់អ្នក ។ បើអ្នកមានយោបល់អ្វីបន្ថែម ឬមានចំណោទ
ដែលអ្នកយល់ឃើញថាត្រូវបន្ថែម ចូរអ្នកសរសេរទៅយើង :

Ontario Youth Secreteriat

Queen's Park, Toronto, Ontario
M7A 1Z1

Ontario

Ministry of
Culture and
Recreation

Multiculturalism
and Citizenship
Division

Hon. Reuben C. Baetz
Minister
Ward Cornell
Deputy Minister

Newcomer Services Branch
5th Floor, 77 Bloor St. W.
Toronto Ontario M7A 2R9
Telephone: 965-2285

THE EDGE on Finding a Job
or Creating Your Own, and
Making the Most of It.

Original English version
produced by the
Ontario Youth Secretariat.

KHMER

D1084 11/81 750

ISBN 0 7743 6802 0